# ទីស្ដីការប្រធានរដ្ឋ

លេខ ០២ ក.ច

## ក្រឹត្យ-ច្បាប់

ស្ដីពីការផ្ដន្ទាទោសក្បត់បដិវត្តន៍

និងបណ្ដាទោសប្រព្រឹត្តបទល្មើសផ្សេងៗ ទៀត

## ក្រុមប្រឹក្សាប្រជាជនបដិវត្ត

- ផ្អែកលើភារកិច្ចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ដែលមានចែងក្នុងសេចក្ដីប្រកាស ចុះថ្ងៃទី ៨ ខែមករា ឆ្នាំ១៩៧៩ ។

- ដើម្បីការពាររដ្ឋអំណាចបដិវត្ត លើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្ត របស់ប្រជាជន រក្សាសន្តិសុខនយោបាយ និង របៀបរៀបរយក្នុងសង្គម ការពារផលប្រយោជន៍របស់រដ្ឋ និង ប្រជាជន។

- តាមសំណើរបស់លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សំរេចចេញក្រឹត្យ-ច្បាប់

**ប្រការ ១**- ត្រូវរកអោយឃើញសបន្ទាន់ ហើយជំនះអោយបានតឹងរ៉ឹង និងប្រកបដោយយុត្តិធម៌ ចំពោះជនទាំងឡាយណាដែលប្រព្រឹត្តអំពើបំពាន លើរបបនយោបាយ សង្គម និងសេដ្ឋកិច្ច លើទ្រព្យសម្បត្តិសាធារណៈ លើរូបរាងកាយ និងផលចយោជន៍សមហេតុ សមផលផ្សេង ៗ របស់ពលរដ្ឋ ។

**ប្រការ ២** - គោលការណ៍នៃការផ្ដន្ទារទេសគឺះ

- ផ្ដន្ទាទោសតឹងរ៉ឹង ចំពោះជនណាដែលជាមេផ្ដើមគំនិត ជាមេខ្លោងដឹកនាំ ជាអ្នកមានឧបាយកលគ្រោះថ្នាក់ មានកលល្បិចសកម្មភាពឃោរឃៅ។ ព្រៃផ្សៃ និង មានឥរិយបថចចេសរឹងរូសប្រឆាំងនឹងបដិវត្តន៍។

អនុគ្រោះត្រាប្រណីចំពោះជនណា ដែលត្រូវពួកក្បត់បដិវត្តន៍វាយបោកបញ្ឆោត វាយបង្ខំអោយបំរើអំពើក្បត់ លើកលែងទោស អត់ឱនទណ្ឌកម្ម ឬសម្រាលទណ្ឌកម្មឱ្យជនទាំងឡាយ ដែលចេញមកសារភាពផ្ទាល់នឹងអង្គការបដិវត្ត ហើយចេះភ្ញាក់រលឹកកែខ្លួនដោយស្មោះ ព្រមទាំងបានរាយការណ៍ វែកមុខពួកក្បត់របស់ខ្លួន ខិតខំបំរើបដិវត្តន៍ បង្កើតស្នាដៃលុបលាងទោសរបស់ខ្លួន។

**ប្រការ ៣**- ទោសក្បត់បដិវត្តន៍

ទោសក្បត់បដិវត្តន៍ពីទោសប្រឆាំងនឹងមាតុភូមិ បំផ្លិចបំផ្លាញឯករាជ្យអធិបតេយ្យភាព ឯករាជ្យបូរណភាពទឹកដី បំផ្លិចបំផ្លាញ រដ្ឋអំណាចបដិវត្ត បំផ្លិចបំផ្លាញកិច្ចការពារប្រទេសរបស់ប្រជាជនកម្ពុជា។

ក - ត្រូវផ្ដន្ទាទោសឃុំខ្លួនពី ១០ ឆ្នាំ ដល់ ២០ឆ្នាំ - ចំពោះជនណាដែល ប្រព្រឹត្តទោសក្បត់ជាតិ ឬ មានឧបាយកលផ្ដួលរំលំរដ្ឋអំណាចប្រជជនបដិវត្ត ។

ខ - ជនណាប្រព្រឹត្តបទចារកម្ម ត្រូវផ្ដន្ទាទោសឃុំខ្លួនជននោះពី ៥ ឆ្នាំ ដល់ ១៥ ឆ្នាំ។

គ- ជនក្បត់បដិវត្តន៍ទាំងឡាយណា ដែលមានសកម្មភាពបង្កចលចល ធ្វើវិទ្ធង្សនា ឬ ប្រមូលកម្លាំងប្រតិកិរិយាប្រើប្រាស់អាវុធដើម្បីប្រឆាំង និង បំផ្លិចបំផ្លាញបដិវត្តន៍ សម្លាប់កម្មាភិបាល កងទ័ព និងប្រជាជន ត្រូវផ្តន្ទាទោស ឃុំខ្លួនជននោះពី ៥ ទៅ ១៥ឆ្នាំ។

ឃ- ជនក្បត់បដិវត្តន៍ ទាំងឡាយណា ដែលបំផ្លិចបំផ្លាញសម្ព័ន្ធសាមគ្គីភាពមហាជន ប្រឆាំងនឹងមាគ៌ានយោបាយក្នុងប្រទេស និងក្រៅប្រទេស របស់រដ្ឋអំណាចបដិវត្ត បំផ្លិចបំផ្លាញកិច្ចការពារប្រទេស ប្រឆាំងនឹងគោលនយោបាយ នានាក្នុងរដ្ឋអំណាចបដិវត្ត បំផ្លិចបំផ្លាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ គមនាគមន៍ កសិកម្ម និងការបង្កបង្កើនផលនានាគឺ ត្រូវផ្តន្ទាទោសឃុំខ្លួនជននោះពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ។

ង- ត្រូវផ្តន្ទាទោសឃុំខ្លួន ២ ឆ្នាំ ដល់ ៧ ឆ្នាំ ចំពោះជនទាំងឡាយណា ដែលបានស្គាល់ច្បាស់អ្នកណាមួយជាជនក្បត់បដិវត្តន៍ហើយ ហើយទៅតែអោយវាស្នាក់អាស្រ័យ ជួយលាក់បំពួន ផ្តល់អាវុធ ផ្តល់ស្បៀងអាហារ និងមធ្យោបាយ អោយពួកក្បត់បដិវត្តន៍។

**ប្រការ ៤-**

ក- ជនណាប្រព្រឹត្តអំពើក្បត់បដិវត្តន៍ដែល បានកំណត់ក្នុងចំណុច ក.ខ.គ.ឃ នៃប្រកាបី ហើយឋិតនៅក្នុងមួយ ឬ ច្រើនចំណុចដូចខាងក្រោម៖

- ធ្វើសកម្មភាពក្បត់បដិវត្តន៍ មានបណ្តាញខ្សែរយៈ និង ការចាត់តាំង ទំហំធំទូលាយ។

- ឆ្លៀតយកមុខតំណែង សិទ្ធិអំណាច ឬឆ្លៀតយកទីដែលមានអារប្រយុទ្ធ ដើម្បីប្រព្រឹត្តអំពើក្បត់បដិវត្តន៍។

- ប្រើកលល្បិចពិសពុល ឃោរឃៅព្រៃផ្សៃ ឬក៏បង្កហេតុផលអាក្រក់ធ្ងន់ធ្ងរ ជាពិសេស។

- ជនប្រព្រឹត្តអំពើក្បត់បដិវត្តន៍ក្នុងពេលបច្ចុប្បន្ន ក៏ដូចជាជនមានទោស ឧក្រិដ្ឋជាច្រើនចំពោះប្រជាជនក្នុងអតីតកាលដែរ។ ជននោះនឹងត្រូវផ្តន្ទាទោសឃុំខ្លួនពី ២០ ឆ្នាំ ដល់អស់មួយជីវិត ឬត្រូវប្រហារជីវិត។

ខ- ជនណាប្រព្រឹត្តទោស ដែលបានកំណត់ក្នុងប្រការបី ហើយឋិតក្នុងមួយ ឬ ច្រើនចំណុចដូចខាងក្រោមនេះ៖

- ជនណាមានទោសហើយចូលខ្លួនផ្ទាល់ មកសារភាពដោយស្មោះ និងរដ្ឋអំណាចបដិវត្ត ហើយស្មោះត្រង់ឆ្លើយរាយការណ៍ច្បាស់លាស់ ឧបាយកលសកម្មភាពរបស់ខ្លួន និងបក្សពួករបស់ខ្លួនជូនរដ្ឋអំណាចបដិវត្តមុនពេលដែលទោសរបស់ជននោះត្រូវប្រជាជនរកែមុខ។

- ជនណាមានទោសដោយត្រូវពួកក្បត់បដិវត្តន៍បង្ខិតបង្ខំ គំរាមកំហែង លួងលោម បោកប្រាស់ ហើយអំពើរបស់ជននោះ ក៏ពុំទាន់បង្កអ្វីអោយខូចខាត អន្តរាយជាធំនៅឡើយ។

ជនមានទោស ត្រូវបានចាប់ខ្លួនមកហើយ តែមុនពេលវិនិច្ឆ័យទោស ជននេះបានបញ្ជាក់អោយឃើញទឹកចិត្តភ្ញាក់រឭកចេះកែខ្លួនដោយស្មោះ ហើយ ចេះខិតខំបង្កើតស្នាដៃបដិវត្តលុបលាងទោសរបស់ខ្លួន។ ជននោះនឹងត្រូវបាន សំរាលទណ្ឌកម្មអត់ឱន ឬ លើកលែងទោសអោយរួចខ្លួន។

**ប្រការ ៥**- ទោសបំពារបំពានលើទ្រព្យសម្បត្តិសាធារណៈ គឺជាទ្រព្យ របស់រដ្ឋ របស់អង្គការសង្គម និង របស់សមូហភពសង្គម។

ជនណាប្រព្រឹត្តបទល្មើសបំពានលើទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសជននោះ ដូចខាងនេះ៖

ក. ជនណា ប្រព្រឹត្តអំពើចោរប្លន់ទ្រព្យសម្បត្តិសាធារណៈ ជននោះ ត្រូវផ្តន្ទាទោសឃុំខ្លួនពី ៥ ឆ្នាំ ដល់ ១៥ ឆ្នាំ។

ខ- ជនណា ប្រព្រឹត្តអំពើបំផ្លិចបំផ្លាញ កំទេចដោយចេតនាទ្រព្យសម្បត្តិសាធារណៈ ជននោះត្រូវផ្តន្ទាទោសឃុំខ្លួនពី ៥ ឆ្នាំ ដល់ ១៥ ឆ្នាំ ។

គ- ត្រូវផ្តន្ទាទោសឃុំខ្លួនពី ១ឆ្នាំ ដល់ ១០ឆ្នាំ ចំពោះជនណាដែលបានឆ្លៀតយកមុខតំណែងសិទ្ធិអំណាច ដើម្បីកិបកេងរឹបយកទ្រព្យសម្បត្តិសាធារណៈ ដែលជននោះមានភារកិច្ចគ្រប់គ្រង និង ទទួលខុសត្រូវ។

ឃ- ជនណា ប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេង។ បំពារបំពានលើទ្រព្យសម្បត្តិសាធារណៈ ដូចជាៈ ចោរលួច បោកប្រាស់ ក្លែងបន្លំ កិបកេង ឆក់ប្លន់។ ជននោះត្រូវផ្តន្ទាទោសឃុំខ្លួនពី ៦ ខែ ដល់ ៧ ឆ្នាំ ។

ង- ត្រូវផ្តន្ទាទោសឃុំខ្លួនពី ៦ ខែ ដល់ ៥ ឆ្នាំ ចំពោះជនណាដែលដឹង ច្បាស់ថាទ្រព្យសម្បត្តិដែលកឹបកេងរឹបយកនោះ ជាទ្រព្យសម្បត្តិសាធារណៈ ហើយនៅតែជួយលាក់បំពួន អោយទុកដាក់ចែកចាយបំបាត់តាង។

ជនណាមានទោសដូចបានកំណត់នៅចំណុច ក.ខ.គ.ឃ. ក្នុងប្រការ ៥ ហើយបង្កហេតុផលអាក្រក់ធ្ងន់ធ្ងរជាពិសេស ជននោះនឹងត្រូវផ្តន្ទាទោសឃុំខ្លួន ពី ២០ ឆ្នាំ ដល់មួយជីវិត ឬត្រូវប្រហារជីវិត ។

**ប្រការ ៦**- ទោសបំពារបំពានលើទ្រព្យសម្បត្តិរបស់ប្រទេសក្រៅ ឬរបស់អង្គការអន្តរជាតិ។

ជនណាបំពារបំពាន លើទ្រព្យសម្បត្តិស្របច្បាប់របស់ប្រទេសអ្នក ឬ របស់អង្គការអន្តរជាតិ លើទឹកដីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជននោះ នឹងត្រូវផ្តន្ទាទោសតាមប្រការ ៥ ក្នុងក្រឹត្យ-ច្បាប់នេះ ។

ក- ជនណា ប្រព្រឹត្តអំពើសម្លាប់មនុស្សតាមវិធីណាក៏ដោយ ត្រូវផ្តន្ទាទោសឃុំខ្លួនជននោះពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ករណីដែលមានលំអិតអាច សម្រាលទណ្ឌកម្មបានគឺ ត្រូវបានសម្រាលទណ្ឌកម្មតាមកំរិតទោសធ្ងន់ស្រាលដែលជននោះបានប្រព្រឹត្ត។ ករណីធ្ងន់ធ្ងរផ្តន្ទាទោសឃុំខ្លួនជនមានទោសនោះដល់អស់មួយជីវិត ឬ កាត់ទោសប្រហារជីវិត ។

ខ - ត្រូវផ្តន្ទាទោសឃុំខ្លួនពី ៦ ខែ ដល់ ៥ ឆ្នាំ ចំពោះជន ណាដែលបង្ករបួសស្នាម ដោយចេតនាដល់អ្នកដទៃ។ ករណីបង្កហេតុផលធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសឃុំខ្លួន ជនមានទោសនោះដល់ទៅ ១០ ឆ្នាំ។

គ- ជនណា ប្រព្រឹត្តបទចាប់ស្ត្រីភេទសពសន្ថវៈជននោះត្រូវផ្តន្ទាទោសឃុំខ្លួនពី ២ ឆ្នាំដល់ ៥ឆ្នាំ ករណីចាប់បង្ខំនារីជំទង់សពសន្ថវៈ ឬ បង្ខំរួមប្រវេណីរួចសម្លាប់ទាំងអ្នក រងគ្រោះនោះ គឺត្រូវផ្តន្ទាទោសឃុំខ្លួនជនមានទោសនោះពី ២០ ឆ្នាំ ដល់អស់មួយជីវិត ឬ កាត់ទោសប្រហារជីវិត។

**ប្រការ ៨**- ទោសបំពារបំពានលើទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន

ជនណាប្រព្រឹត្តបទបំពារបំពានលើទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជន ដូចជា អំពើចោរប្លន់ ចោរលួច បង្ខំទារយកប្រាក់ បន្លំបោកប្រាស់ឆក់ប្លន់ ប្រើអំណាចរឹបយក ឬ បំផ្លិចបំផ្លាញ កំទេចទ្រព្យសម្បត្តិផ្ទាល់របស់ប្រជាជនជន នោះត្រូវផ្តន្ទាទោស ឃុំខ្លួនពី ៦ ខែ ដល់ ៧ ឆ្នាំ។ ករណីធ្ងន់ធ្ងរត្រូវផ្តន្ទាទោសឃុំខ្លួនពី ៨ ឆ្នាំ ដល់ ១៥ ឆ្នាំ។

**ប្រការ ៩**- ទោសបំពារបំពានលើជនបរទេសត្រូវអនុវត្តតាមប្រការ ៧ និងប្រការទី ៨ នៃក្រឹត្យ - ច្បាប់នេះ ចំពោះជនដែលបំពារបំពានលើរូបរាងកាយ ចរិយាសម្បត្តិ និង ទ្រព្យសម្បត្តិរបស់ជនបរទេសលើទឹកដី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

**ប្រការ ១០**- ទោសស៊ីសំណូក

១. ត្រូវផ្តន្ទាទោស ឃុំខ្លួនពី ១ឆ្នាំ ដល់ ១០ឆ្នាំ ចំពោះជនណាដែលឆ្លៀត យកមុខតំណែងសិទ្ធិអំណាចដើម្បីទទួលសំណូក ឬ ទារយកសំណូក ។ របស់របរជាសំណូកទាំងអស់ត្រូវរឹបយក។

២- ជនណាប្រព្រឹត្តបទប្រគល់សំណូក ឬ ធ្វើជាអ្នកកណ្តាលក្នុងបទសូកប៉ាន់ បានត្រូវផ្តន្ទាទោសដូចជនទទួលសំណូក ឬ ចារយកសំណូករនេះដែរ។

ក្នុងករណីដែលអ្នកប្រគល់សំណូកត្រូវគេបង្ខំ ហើយក្រោយពីការប្រគល់ សំណូក បានទៅប្តឹងនឹងក្រសួងមានសមត្ថកិច្ច អ្នកនោះឯង នឹងត្រូវបានលើកលែង អត់ឱនទណ្ឌកម្មហើយ និងអោយទទួលមកវិញនូវរបស់របរជាសំណូកនោះ។

**ប្រការ ១១**- អំពីប្រសិទ្ធភាព នៃក្រឹត្យ-ច្បាប់ ។

អំពីប្រព្រឹត្តបទល្មើសទាំងឡាយដែលកើតមានឡើងក្រោយថ្ងៃ៧ មករា ១៩៧៩ រហូតមកដល់ថ្ងៃប្រកាសក្រឹត្យ - ច្បាប់នេះ ហើយមិនទាន់បានជំនុំជំរះគឺត្រូវចោទប្តឹងទៅតុលាការ និងជំនុំជំរះតាមក្រឹត្យ -ច្បាប់នេះ។

**ប្រការ ១២**- លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចណែនាំអនុវត្តក្រឹត្យ - ច្បាប់នេះ។

ភ្នំពេញ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៨០

ជ. ប្រុមប្រឹក្សាប្រជាជនបដិវត្ត

ប្រធាន

**ហេង សំរិន**